ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៣២/១៥-ខេមបូឌាន ហ៊ែនលីហ្វ ប្រដាក់
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង វួចហ៊ុន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **រុន សាវ៉ាយ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ខេមបូឌាន ហ៊ែនលីហ្វ ប្រដាក់**

អាសយដ្ឋាន ៖ តំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ

ទូរស័ព្ទ ៖ ០៩៣ ៩៨១ ១៦៦/០៩៧ ២០៥ ៨៨ ៩៥ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

១- Mr. Zhuyonrun នាយកគ្រប់គ្រងទូទៅ

២- លោក ញ៉ើង សុខា បកប្រែ

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ**

អាសយដ្ឋាន ៖ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨៩ ៧៤៤ ៦៧៧/០១៥ ៧០០ ៧១៥ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖ អវត្តមាន ។

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

## បញ្ហាក្តូងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- នៅពេលកម្មករធ្វើការងារក្នុងក្រុមហ៊ុនបានមួយឆ្នាំ សូមឱ្យក្រុមហ៊ុនគិតលុយជូសការឈប់សម្រាកប្រចាំឆ្នាំចំនួន ១៨ ថ្ងៃ តាមច្បាប់ស្តីពីការងារ។

២- ក្នុងកំឡុងពេលកូដកម្ម សូមឱ្យក្រុមហ៊ុនរក្សាអត្ថប្រយោជន៍ផ្សេងៗ នៅដដែល។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃ ប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣០ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ (អាណត្តិទី១២)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេមបូឌាន ហ៊ែនលីហ្វ ប្រដាក់ លេខ ០៣៩៩/១៥ កប/ស.ត.ស.៣ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងជួបប្រជុំសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល “ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ” ។

**កាលបរិច្ឆេទសវនាការ ៖**

- ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល )។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ការិយាល័យតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រចាំតំបន់សេដ្ឋកិច្ចក្រុងព្រះសីហនុ បានទទួលលិខិតស្នើសុំឱ្យជួយដោះស្រាយករណីកូដកម្មនៅក្រុមហ៊ុន ខេមបូឌាន ហ៊ែនលីហ្វ ប្រដាក់។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក ការិយាល័យតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងបានធ្វើការផ្សះផ្សាចុងក្រោយ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០២ ចំណុច លើការទាមទារចំនួន ០៤ ចំណុច។ ចំណុចមិនសះជាដែលនៅសល់ចំនួន ០២ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅ

ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេមបូឌាន ហែនលីហ្វ ប្រដាក់ លេខ ០៣៥៩/១៤ កប/ស.ត.ស.៣ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៤ ចំណុចនេះ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០១៥ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ ភាគីនិយោជកបានមានវត្តមាន នៅថ្ងៃសវនាការតាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចំណែកឯភាគីកម្មករនិយោជិត មិនបានមានវត្តមាននៅក្នុងសវនាការតាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ នៅថ្ងៃសវនាការ វេលាម៉ោង ១៣៖៥០នាទី រសៀល លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទំនាក់ទំនងតាមរយៈទូរស័ព្ទទៅមន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ពាក់ព័ន្ធនឹងការចូលរួមសវនាការ ហើយមន្ត្រីសហព័ន្ធបានឆ្លើយតបតាមទូរស័ព្ទថា សុំពន្យាពេលសវនាការនៅថ្ងៃផ្សេង ដោយហេតុថា សហព័ន្ធបានភ្លេចកាលបរិច្ឆេទសវនាការ និងមិនបានប្រាប់ដំណឹងពីថ្ងៃសវនាការនេះទៅកម្មករនិយោជិតផ្ទាល់។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការសាកសួរទៅភាគីនិយោជកអំពីការស្នើសុំលើកថ្ងៃសវនាការនេះ ប៉ុន្តែ ភាគីនិយោជកបានបដិសេធចំពោះការស្នើសុំនេះ។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល នៃសំណុំរឿងនេះ គឺនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតរបស់ក្រុមហ៊ុន Cambodian Handlift Product គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិត ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥។

២- របាយការណ៍របស់ក្រុមហ៊ុន ខេមបូឌាន ហែនលីហ្វ ប្រដាក់ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជូនកំណត់ហេតុវិវាទរវាងកម្មករនិយោជិត និងក្រុមហ៊ុន ខេមបូឌាន ហែនលីហ្វ ប្រដាក់។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខេមបូឌាន ហែនលីហ្វ ប្រដាក់ លេខ ២០៣៥៩/១៥ កប/ស.ត.ស.៣ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥។

THE ARBITRATION COUNCIL

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ខេមបូឌាន ហ៊ែនលីហ្វ ប្រដាក់ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៧២៥ កប/អក/វក/លកអ. ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៧២៦ កប/អក/វក/លកអ. ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥។

៤- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០១៩/១៥ កបអ. ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ ២០១៥។

**អង្គហេតុ ៖**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងការទាមទារនៅក្នុងរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន ខេមបូឌាន ហ៊ែនលីហ្វ ប្រដាក់ ដែលបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយ ការិយាល័យតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រចាំតំបន់សេដ្ឋកិច្ចក្រុងព្រះសីហនុ ដោយហេតុថា ភាគីកម្មករនិយោជិតដែលជាដើមបណ្តឹងមិនមានវត្តមាននៅថ្ងៃសវនាការ ។

**ហេតុផលនៃសេចក្តីសម្រេច៖**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ ក្នុងករណីអវត្តមានភាគីកម្មករនិយោជិតដែលជាភាគីដើមបណ្តឹង?

ប្រការ ១៨ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"ក្រុមអាជ្ញាកណ្តាលត្រូវអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់ នូវការអះអាងរបស់ខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងដាក់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀត"*។

ប្រការ ២០ នៃប្រកាសខាងលើដដែលនេះ ចែងថា ៖ *"...ភាគីវិវាទ...ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម ។"*

ប្រការ ២១ នៃប្រកាសខាងលើដដែលនេះ ចែងថា៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់ "* ។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃ

THE ARBITRATION COUNCIL

ទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាលមុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"* ។

យោងតាមប្រការ ១៨ ប្រការ ២០ និងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ ខាងលើ និងវិធាន ៤.៧ នៃ ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ ខាងលើនេះ ខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនៃវិវាទមានកាតព្វកិច្ចត្រូវចូលរួមរាល់កិច្ចប្រជុំទាំងអស់ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញ។ ក្នុងករណីដែលភាគីណាមួយ មិនបានចូលរួមតាមការអញ្ជើញនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចសម្រេចបន្តដំណើរការអាជ្ញាកណ្តាល ដោយអវត្តមានភាគី ឬបញ្ចប់ដំណើរការអាជ្ញាកណ្តាលបាន។ ការសម្រេចជ្រើសរើសជម្រើសណាមួយនៃជម្រើសទាំងពីរនេះ ត្រូវបំពេញនូវលក្ខខណ្ឌបី គឺលក្ខខណ្ឌទី១- ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ លក្ខខណ្ឌទី២- ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល និងលក្ខខណ្ឌទី៣- ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានបកស្រាយដែរថា មានលក្ខខណ្ឌបីដែលត្រូវបំពេញដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន។ លក្ខខណ្ឌទី១ គឺ ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ លក្ខខណ្ឌទី២ គឺ ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ គឺ ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៣០/០៥-មូរៀ លេខ ១៦/០៧-ឡូទូសតី លេខ ២៧/០៧-អ៊ឹម និង វ៉េ ៣ លេខ ៩៥/ ០៨-យ៉ុង វ៉ា ទី១ លេខ ១៣២/០៨-ជី អេច ជី លេខ ១៣៨/០៨-ម៉ាលីន លេខ ១៥១/០៨-វិល សិន លេខ ០៩/ ០៩-នីមបឹសថិចថាយ៍ លេខ ០១/១០-ខិននីតិច លេខ ៣០/១០-ក្លូប៉ល អាប៉ារែល លេខ ១៣០/១៣- យែន ធើរេន អីកែរីល លេខ ១៦៧/១៣- ឃ្វីនធ៍ មេជើរ អ៊ិនដាសស្ទ្រៀល និងលេខ ២៧០/១៣-៨ ស្តារ ស្ពតវែរ)* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗខាងលើដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបី នេះត្រូវបានបំពេញដែរឬទេ?

*លក្ខខណ្ឌទី ១- ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ*

លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីកម្មករនិយោជិតដែលជាដើមបណ្តឹងឱ្យមកចូលរួមសវនាការអាជ្ញាកណ្តាលយ៉ាងត្រឹមត្រូវ តាមរយៈលិខិតលេខ ៧២៦ កប/អក/វក/លកអ. ចុះថ្ងៃ១៧ ខែមិថុនា ឆ្នាំ២០១៥ ដោយមានបញ្ជាក់យ៉ាងច្បាស់លាស់អំពីកាលបរិច្ឆេទនៃសវនាការ ទីកន្លែងនៃសវនាការ ព្រមទាំងលេខទូរស័ព្ទ និងទូរសារ សម្រាប់ទំនាក់ទំនងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ នៅថ្ងៃសវនាការ លេខាធិការដ្ឋានក្រុម

ប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការទាក់ទងតាមរយៈទូរស័ព្ទម្តងទៀតទៅកាន់ភាគីកម្មករនិយោជិតដើម្បីឱ្យមកចូលរួមសវនាការ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដើមបណ្តឹងពិតជាទទួលបានការអញ្ជើញ និងជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃសវនាការអាជ្ញាកណ្តាល។ ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ២- ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា *"ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល"* នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានន័យថា ភាគីត្រូវតែមាន ១-វត្តមាននៅក្នុងសវនាការ និង ២-ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់។ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

បន្ថែមលើនេះ ប្រការ ១៩ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចែងថា៖ *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយផ្ទាល់ខ្លួន ឬ ដោយមានអ្នកអម ឬតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"*។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតដែលជាភាគីដើមបណ្តឹង មិនបានបង្ហាញវត្តមាននៅថ្ងៃសវនាការអាជ្ញាកណ្តាលនោះទេ គឺមានន័យថា មិនបានចូលរួមគ្រប់ដំណាក់កាលទាំងបួនខាងលើនេះ និងមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលតាមខ្លឹមសារនៃប្រការ ២១ នៃប្រកាសលេខ ០៩៩ ទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនបានមកចូលរួមសវនាការទេ។ ហេតុនេះ លក្ខខណ្ឌទី២ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ៣- ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

នៅក្នុងសំណុំរឿងនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានជូនដំណឹងតាមរយៈទូរស័ព្ទ ទៅភាគីកម្មករនិយោជិត អំពីសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នៅថ្ងៃសវនាការ វេលាម៉ោង ១៤ និង ០៥ នាទីរសៀល មន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ បានឆ្លើយតបតាមទូរស័ព្ទថា សុំពន្យាពេលសវនាការទៅថ្ងៃផ្សេង ដោយហេតុថា សហព័ន្ធបានភ្លេចកាលបរិច្ឆេទសវនាការ និងមិនបានប្រាប់ដំណឹងពីថ្ងៃសវនាការនេះទៅកម្មករនិយោជិតផ្ទាល់។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ឃើញថា ភាគីកម្មករនិយោជិតមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះឡើយ។ ដូចនេះ លក្ខខណ្ឌទី៣ ត្រូវបានបំពេញ។

សរុបសេចក្តីមក លក្ខខណ្ឌទាំងបីដែលមានចែងក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ ត្រូវបានបំពេញ។

បន្ថែមពីលើនេះ នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិត គឺជាដើមបណ្តឹង។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ឃើញថា កាតព្វកិច្ចរបស់ភាគីដើមបណ្តឹង និងភាគីចុងបណ្តឹងនៃសំណុំរឿងវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺត្រូវមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួន ក៏ដូចជាផ្តល់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗដែលពាក់ព័ន្ធនឹងចំណុចវិវាទសម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងសម្រេចសេចក្តី។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងទាមទាររបស់ខ្លួន។ ចំណែកឯភាគីចុងបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធ នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះបន្ទុករបស់ខ្លួនពីការទាមទារ ឬការចោទប្រកាន់ពីសំណាក់ដើមបណ្តឹង ដែលកាតព្វកិច្ចនេះ ជាទូទៅ នឹងត្រូវកើតឡើងក្រោយពេលដែលដើមបណ្តឹងបានបំពេញកាតព្វកិច្ចរបស់ខ្លួនជាមុនសិន។

ក្នុងសំណុំរឿងនេះ ដើមបណ្តឹងមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបំពេញនូវកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ លើសពីនេះ ភាគីដើមបណ្តឹងក៏មិនមានមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា ដើមបណ្តឹងបានបោះបង់ចោលការទាមទាររបស់ខ្លួន។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនចាំបាច់បន្តដំណើរការអាជ្ញាកណ្តាលនោះទេ។

ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ១៣២/១៥-ខេមបូឌាន ហ៊ៃនលីហ្វ ប្រដាក់ ដោយចេញសេចក្តីបង្គាប់។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

## សម្រេច

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ១៣២/១៥-ខេមបូឌាន ហ៊ៃនលីហ្វ ប្រដាក់។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ៖ **សេខ ទួចហ៊ុន**

ហត្ថលេខា៖ ------------------------------

THE ARBITRATION COUNCIL

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល

ឈ្មោះ ៖ **រុន សារ៉ាយ**

ហត្ថលេខា ៖ ------------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL